ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ២០១០ សរ សរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីពិភាក្សា និងសម្របសម្រួល ការផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត នស/រកត/០៩១/០៩៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀប ចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន។

# សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីពិភាក្សា និងសម្របសម្រួលក្នុងការផ្ទេរមុខងារការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដូចមានសមាសភាពខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ឈិត សុខុន** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | ប្រធាន |
| ២. ឯកឧត្តម **ស៊ូ សុទ្ធុង** | អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន | អនុប្រធាន |
| ៣. ឯកឧត្តម **ចាន់ សុធា** | អគ្គនាយករង ក្រសួងមហាផ្ទៃ | សមាជិក |
| ៤. ឯកឧត្តម **គីម ទត្តវានសោភ័ណ** | អគ្គនាយករង ក្រសួងមហាផ្ទៃ | សមាជិក |
| ៥. ឯកឧត្តម **ឡេីន សុខា** | អគ្គនាយករង ក្រសួងបរិស្ថាន | សមាជិក |
| ៦. ឯកឧត្តម **ហ៊ុំង ច័ន្ទបូរ៉ា** | អគ្គនាយករង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧. ឯកឧត្តម **ម៉ុន បុណ្ណារិទ្ធ** | អគ្គនាយករង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨. លោក **ប៊ួន ហេង** | ប្រធាននាយកដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ៩. លោក **ជា ស៊ីណា** | ប្រធាននាយកដ្ឋាន ក្រសួងបរិស្ថាន | សមាជិក |
| ១០. លោក **ទី គីដែន** | ប្រធាននាយកដ្ឋាន ក្រសួងបរិស្ថាន | សមាជិក |
| ១១. លោក **ហៃ សុទ្ធធា** | ប្រធាននាយកដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២. លោក **ហុក ជាឌុង** | អនុប្រធាននាយកដ្ឋាន ក្រសួងមហាផ្ទៃ | សមាជិក |
| ១៣. លោក **សារុន សំបូរ** | អនុប្រធាននាយកដ្ឋាន ក្រសួងបរិស្ថាន | សមាជិក |
| ១៤. លោក **ជា គីមឈុង** | អនុប្រធាននាយកដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៥. លោក **ហួយ ខចិត្រ** | ប្រធានការិយាល័យ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៦. លោក **ទី សេងគី** | មន្ត្រីនាយកដ្ឋានមុខងារ និងធនធាន ក្រសួងមហាផ្ទៃ | សមាជិក |
| ១៧. លោក **ថាច់ សាទី** | ទីប្រឹក្សា លេខាធិការដ្ឋាន គ.ជ.អ.ប | សមាជិក |
| ១៨. លោក **ចេង ម៉ានី** | ទីប្រឹក្សា លេខាធិការដ្ឋាន គ.ជ.អ.ប | សមាជិក។ |

**ប្រការ២.-**

ក្រុមការងារអន្តរក្រសួងនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួលជាមួយរដ្ឋបាលខេត្តក្នុងការផ្ទេរការអនុវត្ត និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលក្រុង ស្រុក
- សម្របសម្រួលជាមួយរដ្ឋបាលរាជធានីក្នុងការផ្ទេរមុខងារមួយផ្នែក ឬទាំងស្រុងក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលខណ្ឌ ឬ/និងរដ្ឋបាលឃុំ សង្កាត់

- សហការ និងគាំទ្រដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកក្នុងការត្រួតពិនិត្យការអនុវត្តកិច្ចសន្យាផ្តល់សេវាសំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ ដើម្បីកែសម្រួលកិច្ចសន្យាទាំងនោះឱ្យស្របតាមខ្លឹមសារនៃអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- រៀបចំនីតិវិធីនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ចំណូលពីការពិន័យអន្តរការណ៍
- រៀបចំដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តិ ឬ/និងគោលការណ៍ចាំបាច់នានាសម្រាប់ណែនាំដល់ការអនុវត្តការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

**ប្រការ៣.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធាននាយកដ្ឋានមុខងារ និងធនធាន ក្រសួងមហាផ្ទៃ និងសាមីខ្លួនដូចមានរាយនាមក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ក្រសួងបរិស្ថាន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

  *«ដើម្បីជូនជ្រាប»*
- ដូចប្រការ៣

  *«ដើម្បីអនុវត្ត»*
- ឯកសារ - កាលប្បវត្តិ